ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែឧសភា ឆ្នាំ២០២០

នៅក្នុងខែឧសភា ឆ្នាំ២០២០នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅៈ

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០១លើក។

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០១លើក។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-អញ្ជើញចូលរួមទទួលព្រះរាជដំណើររបស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្តេចយាងនិវត្តន៍ពីសាធារណៈរដ្ឋប្រជាមានិតចិនមកកាន់មាតុប្រទេសវិញ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាដាក់កម្រងផ្កា គោរពវិញ្ញាណក្ខន្ធសពអ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកាធម្មញ្ញាណវិវឌ្ឍនា **ប៊ុន ស៊ាងលី** ត្រូវជាមាតាសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងជាមាតាក្មេក**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅសង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមពិធីបញ្ចុះសពអ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកាធម្មញ្ញាណវិវឌ្ឍនា **ប៊ុន ស៊ាងលី** នៅឃុំរការខ្នុរ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

-អញ្ជើញចូលរួមពិធីបុណ្យទក្ខិណានុប្បទានគម្រប់៧ថ្ងៃ ឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធអ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកាធម្មញ្ញាណវិវឌ្ឍនា **ប៊ុន សាងលី** នៅឃុំ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum sarith@camnet.com.kh

វការខ្មុរ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអតីតរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា នៅបុរីប៉េងហួតបឹងស្នោ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

**គ-សកម្មភាពចុះមូលដ្ឋាន**

-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខជាមួយបងប្អូនប្រជាពលរដ្ឋនៅភូមិកំណើតរបស់សម្តេច នាភូមិកណ្តាលកោះ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម

-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខ ចាស់ព្រឹទ្ធាចារ្យ បងប្អូនប្រជាពលរដ្ឋ និងថ្វាយបង្គំព្រះសង្ឃ នៅវត្តគគី ឃុំព្រៃកអាជី ស្រុកក្រូចឆ្មា ខេត្តត្បូងឃ្មុំ

-អញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខមន្ត្រី និងអាជ្ញាធរសង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

-អញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខមន្ត្រី និងអាជ្ញាធរសង្កាត់ប្រទះឡាង ខណ្ឌកំបូល រាជធានីភ្នំពេញ

-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខមន្ត្រី និងអាជ្ញាធរសង្កាត់បឹងធំ ខណ្ឌកំបូល រាជធានីភ្នំពេញ។

**ឃ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ចុះហត្ថលេខាលើព្រះរាជក្រមចំនួន០១ច្បាប់

-ចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៣៧ច្បាប់

-ទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន៣៩ច្បាប់ ទទួលសំណើពីរដ្ឋសភាចំនួន០១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២០ច្បាប់

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៧ច្បាប់។

## ១.២ ឯកឧត្តម ស៊ុម កា អនុប្រធានទី១ព្រឹទ្ធសភា បាន

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក។

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-អញ្ជើញដឹកនាំកិច្ចប្រជុំ និងចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន០២លើក

-អញ្ជើញចូលរួមប្រជុំផ្ទៃក្នុងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-អញ្ជើញចូលរួមក្នុងពិធីគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអតីតរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា នៅបុរីប៉េងហួតបឹងស្នោ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ និងពិធីបូជាសព**ឯកឧត្តម កែវ ធី** ទីប្រឹក្សាសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តពោធិព្រឹក្ស សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

**គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៤ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៦ច្បាប់។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា ប្អាន**

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភាចំនួន ០២លើក។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-អញ្ជើញចូលរួមក្នុងពិធីបុណ្យ និងពិធីបញ្ចុះសពអ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកាធម្មញ្ញាណវិវឌ្ឍនា **ប៊ុន ស៊ាងលី** នៅឃុំរការខ្នុរ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

-អញ្ជើញចូលរួមក្នុងពិធីគោរពវិញ្ញាណក្ខន្ធសព**ឯកឧត្តម ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអតីតរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា នៅបុរីប៉េងហួតបឹងស្នោ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

### គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១១ច្បាប់។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានបើកកិច្ចប្រជុំចំនួន០២លើក ដែលមានរបៀបវារៈដូចខាងក្រោម៖

១-ការធ្វើវិចារណកម្មថវិកាព្រឹទ្ធសភាលើកទី២ ក្នុងក្រខ័ណ្ឌច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

២-ពិនិត្យ និងសម្រេចអំពីការរៀបចំរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឱ្យបានស្របនឹងតម្រូវការថ្មីរបស់ស្ថាប័ន។

## ៣-សកម្មភាពប្រយុទ្ធនឹងជំងឺកូវីដ១៩

ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបន្តបរិច្ចាគប្រាក់បៀវត្សផ្ទាល់ខ្លួន គ្រឿងឧបភោគ បរិភោគ និងសម្ភារៈការពារ ព្រមទាំងបានចុះអប់រំ ផ្សព្វផ្សាយអំពីវិធានការការពារ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ជូនប្រជាពលរដ្ឋ និងអាជ្ញាធរថ្នាក់ក្រោមជាតិ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

## ៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

ក្នុងខែឧសភានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១ មុខងារតំណាង

-ទទួលពាក្យបណ្តឹងបានចំនួន០៣ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបានចំនួន០៣ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងបានចំនួន០៣ករណី និងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ដើម្បីជូនជ្រាបបានចំនួន០២ករណី

-ប្រជុំផ្សព្វផ្សាយអំពីស្មារតី នៃកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

ស្តីពីការធ្វើវិចារណកម្មថវិកាព្រឹទ្ធសភាលើកទី២ ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

-សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ប្រជុំពិនិត្យស្ថានភាពថវិកា និងរបាយការណ៍សកម្មភាពរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ប្រចាំខែឧសភា ឆ្នាំ២០២០

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបពិភាក្សាការងារ សំណេះសំណាលសាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ពង្រឹងការគោរពច្បាប់ចរាចរណ៍ និងផ្សព្វផ្សាយវិធីបង្ការ និងទប់ស្កាត់ជំងឺកូវីដ១៩ដល់ប្រជាពលរដ្ឋ និងពលករមកពីបរទេស ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន១១៧លើក។

## ៤.២ មុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ ទទួលជួបគណៈប្រតិភូកូរ៉េតំណាងឱ្យក្រុមហ៊ុន HYUNDIA និងគណៈប្រតិភូមកពីសាធារណរដ្ឋប្រជាមានិតចិន ដើម្បីរកទីផ្សារនាំចេញផ្លែស្វាយរបស់កសិករកម្ពុជា និងរកឱកាសបង្កើតការងារឱ្យប្រជាជនកម្ពុជា

-លោកជំទាវ **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ អនុញ្ញាតឱ្យលោកជំទាវ **លីយ៉ូរកា រ៉ូឌ្រីហ្គេស បារីស** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋគុយបា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសវនាការ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

*ចម្លងជូន*

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*